# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ...៧៥ អនក្រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការទប់ស្កាត់ការធ្វើអន្តោប្រវេសន៍ខុសច្បាប់ នៅខេត្តរតនគិរី មណ្ឌលគិរី និងខេត្តក្រចេះ

✧✧✧✧✧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីអន្តោប្រវេសន៍
- យោងតាមសំណើរបស់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ

## <u>សម្រេច</u>

**<u>ប្រការ១:</u>** ត្រូវបានបង្កើតគណៈកម្មការទប់ស្កាត់ការធ្វើអន្តោប្រវេសន៍ខុសច្បាប់នៅខេត្តរតនគិរី មណ្ឌលគិរី និងខេត្តក្រចេះ ដែលតាមខេត្តនិមួយៗមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-**ឯកឧត្តមអភិបាលខេត្ត** | ជាប្រធាន |
| ២-**លោកស្នងការនគរបាលខេត្ត** | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៣-**លោកមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត** | ជាសមាជិក |
| ៤-**លោកមេបញ្ជាការវរៈការពារព្រំដែនប្រចាំខេត្ត** | ជាសមាជិក |

**<u>ប្រការ២:</u>** គណៈកម្មការទប់ស្កាត់ការធ្វើអន្តោប្រវេសន៍ខុសច្បាប់នេះមានភារកិច្ច :

- ដឹកនាំអនុវត្តអោយបានត្រឹមត្រូវតាមច្បាប់អន្តោប្រវេសន៍

-ចាត់វិធានការគ្រប់បែបយ៉ាង រក្សាការពារខ្សែបន្ទាត់ព្រំដែនទប់ស្កាត់រាល់ការជ្រៀតចូលដោយខុសច្បាប់របស់ជនបរទេសទាំងឡាយ មកក្នុងព្រះរាជាណាចក្រកម្ពុជា ។

-ជនបរទេសដែលជ្រៀតចូលខុសច្បាប់តាមច្រកទ្វារណា ឬ បៀងណា ត្រូវចាត់បញ្ជូនចេញទៅវិញតាមច្រកទ្វារ និងបៀងនោះវិញ ។

-ត្រូវចាត់វិធានការសហប្រតិបត្តិការជាមួយអាជ្ញាធរប្រទេសជិតខាង ដែលមានព្រំប្រទល់ជាប់គ្នា ដើម្បីមានផែនការទប់ស្កាត់រាល់ការចេញចូលដោយខុសច្បាប់ មកក្នុងប្រទេសទាំងសង្ខាង ។

-រាល់ករណីដែលមិនស្ថិតក្នុងសមត្ថកិច្ចដោះស្រាយរបស់ខេត្ត ត្រូវរាយការណ៍ជាបន្ទាន់មកក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ដើម្បីមានវិធានការដោះស្រាយ ។

-រៀងរាល់ខែគណៈកម្មការត្រូវរាយការណ៍អំពីស្ថានភាពទូទៅ និងលទ្ធផលកិច្ចប្រតិបត្តិការព្រមទាំងទិសដៅវិធានការជូនក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**ប្រការ៣:** គណៈកម្មការទប់ស្កាត់ការធ្វើអន្តោប្រវេសន៍ខុសច្បាប់ មានសិទ្ធិប្រើប្រាស់កម្លាំង និងមធ្យោបាយដែលមានស្រាប់ស្ថិតក្រោមឱវាទ ដើម្បីដោះស្រាយការងារដែលមានការពាក់ព័ន្ធ ។

-សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីចាំបាច់ប្រធានគណៈកម្មការមានសិទ្ធចាត់សមាជិកម្នាក់អោយដឹកនាំការងារចុះត្រួតពិនិត្យជំនួស ។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ អគ្គនាយករដ្ឋបាល និងឯកឧត្តម អស់លោកក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០២

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ដូចប្រការ១ និងប្រការ៤

-ឯកសារ-កាលប្បវត្តិ